**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខៈ ០០១៦...រ៉.ថ.ព/អាឧរ.សជណ

ថ្ងៃ សុក្រ ១០រោចខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកតំបន់សម្បទានស្វែងរុករករ៉ែ សម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក

ក្រសួងរ៉ែ និងថាមពល មានសេចក្តីសោមនស្សជម្រាបជូនដល់សាធារណជន បណ្តាក្រុមហ៊ុនជាតិ និងអន្តរជាតិ ឱ្យបានជ្រាបថា ក្រសួងរ៉ែ និងថាមពល សូមប្រកាសបើកឱ្យដាក់ពាក្យប្រកួតប្រជែងជាសាធារណៈ សម្រាប់ទទួលបានអាជ្ញាបណ្ណស្វែងរុករក ចំពោះតំបន់សម្បទានស្វែងរុករករ៉ែចំនួន ០១ (មួយ) តំបន់ លើផ្ទៃដីទំហំ ១៥៥ (មួយរយហាសិបប្រាំ) ហិកតា ស្ថិតនៅក្នុងតំបន់ភ្នំទ្វារប្រាំបី និងភ្នំជ្រោះកណ្តាល នៅឃុំតាកែន ស្រុកឈូក ខេត្តកំពត ដូចមាន "ផែនទីទីតាំង និងកូអរដោណេ" ជូនភ្ជាប់មកជាមួយ។

សាធារណជន បណ្តាក្រុមហ៊ុនជាតិ និងអន្តរជាតិ ដែលចាប់អារម្មណ៍ សូមស្នើសុំ "ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក" នៅ**នាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធានរ៉ែ** (ជាន់ទី៣) នៃទីស្តីការក្រសួងរ៉ែ និងថាមពល ដែលមានអាសយដ្ឋាន អគារC មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ម៉ោងធ្វើការ។

ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករករ៉ែ ដែលបានបំពេញរួចរាល់ ត្រូវភ្ជាប់មកជាមួយនូវឯកសារ និងរបាយការណ៍តម្រូវពាក់ព័ន្ធ ហើយដាក់ក្នុងស្រោមសំបុត្របិទជិតដោយការខ្ទង់ "ឯកសារស្នើសុំប្រកួតប្រជែង" រួចប្រគល់ជូន "**ការិយាល័យច្រកចេញចូលតែមួយ**" របស់ក្រសួងរ៉ែ និងថាមពល យ៉ាងយូរបំផុតត្រឹម**ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង១៧៖០០នាទី**។

ប្រធានក្រុមហ៊ុនសូមអញ្ជើញមកដាក់សំណុំឯកសារសុំអាជ្ញាបណ្ណស្វែងរុករករ៉ែដោយផ្ទាល់ ឬប្រគល់សិទ្ធិជូនអ្នកតំណាងរបស់ខ្លួន ដោយភ្ជាប់មកជាមួយ "លិខិតប្រគល់សិទ្ធិ" ពីប្រធានក្រុមហ៊ុន។

ក្រសួងរ៉ែ និងថាមពល នឹងប្រកាសផ្សាយជាសាធារណៈ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលជ័យលាភី ដែលក្រសួងសម្រេចជ្រើសរើសនិងផ្តល់អាជ្ញាបណ្ណស្វែងរុករកជូន បន្ទាប់ពីបានអនុវត្តតាមនីតិវិធីចប់សព្វ



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

គ្រប់ស្របតាមអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ និងបានដោះស្រាយបណ្តឹងតវ៉ាចប់រួចរាល់ជាស្ថាពរ។

ព័ត៌មានលម្អិតសូមទំនាក់ទំនង៖

ទូរស័ព្ទលេខ៖ - ០១៧ ២៣៣ ២៣៤
- ០១២ ២០១ ៧៥០
- ០៦៩ ៨៤៤ ៤៤៨

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន៖**

- គ្រប់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត "ដើម្បីជ្រាប និងផ្សព្វផ្សាយបន្ត"
- ឯកសារ-កាលប្បវត្តិ

# ផែនទីទីតាំងតំបន់សម្បទានរ៉ែសម្រាប់ផ្តល់អាជ្ញាបណ្ណស្វែងរុករករ៉ែនៅតំបន់ភ្នំទ្វារប្រាំបី និងភ្នំជ្រោះកណ្តាល ឃុំតាកែន ស្រុកឈូក ខេត្តកំពត




**កំណត់សម្គាល់៖**

តំបន់សម្បទានធនធានរ៉ែ

N
W E
S

មាត្រដ្ឋាន 1:25,000

0 0.35 0.7 1.4 Kilometers

| និយាមកាតំបន់សម្បទានស្វែងរុករកធនធានរ៉ែ | | | | | |
|---|---|---|---|---|---|
| ចំណុច | អាប់ស៊ីស | អរដោនេ | ចំណុច | អាប់ស៊ីស | អរដោនេ |
| A | 428688 | 1201905 | H | 428845 | 1200777 |
| B | 429531 | 1202126 | I | 428483 | 1200872 |
| C | 429845 | 1202365 | J | 428481 | 1201107 |
| D | 430360 | 1201258 | K | 429018 | 1201215 |
| E | 430005 | 1201042 | L | 428970 | 1201355 |
| F | 429751 | 1201357 | M | 428720 | 1201322 |
| G | 428999 | 1200836 | | | |
| ទំហំផ្ទៃដីសរុប ១៥៥ ហិកតា | | | | | |

| Coordination System | |
|---|---|
| Projection: | UTM |
| Zone: | 48N |
| Horizontal Datum: | WGS1984 |
| Spheroid: | Everest |